# ខោនធី LOS ANGELES
# មន្ត្រីចុះបញ្ជី-មន្ត្រីកត់ត្រា/ស្មៀនខោនធី

## សុវត្ថិភាព

ផ្ដល់ជូនអ្នកបោះឆ្នោតនៅខោនធី Los Angeles នូវបទពិសោធន៍ក្នុងការបោះឆ្នោតដែលមានសុវត្ថិភាព ត្រឹមត្រូវ និងតម្លាភាព ។

**គំរូដំណោះស្រាយបោះឆ្នោតសម្រាប់ប្រជាជនទាំងអស់ (VSAP) ត្រូវបានរចនាឡើងដើម្បីឱ្យមានសុវត្ថិភាព និងតម្លាភាពសម្រាប់អ្នកបោះឆ្នោតទាំងអស់។ មានធាតុប្រព័ន្ធផ្សេងៗដែលការពារសុចរិតភាពនៃការបោះឆ្នោត និងដំណើរការបោះឆ្នោត។**

### ការរចនាប្រកបដោយសុវត្ថិភាព

ឧបករណ៍គូសសន្លឹកឆ្នោត (BMD) បោះពុម្ពសន្លឹកឆ្នោតក្រដាសដែលអ្នកបោះឆ្នោតអាចផ្ទៀងផ្ទាត់បាន ។ ជម្រើសរបស់អ្នកបោះឆ្នោតត្រូវបានបោះពុម្ពក្នុងទម្រង់ជាអត្ថបទដែលអាចឱ្យមនុស្សអានបាន និងជាកំណត់ត្រាការបោះឆ្នោតផ្លូវការ ។ តាមរយៈការរៀបចំនេះ BMD មិនត្រូវបានភ្ជាប់ទៅកាន់បណ្ដាញណាមួយ ឬអ៊ីនធឺណិតឡើយ ។ វាមិនរក្សាទុកនូវទិន្នន័យរបស់អ្នកបោះឆ្នោត ឬចំនួនការបោះឆ្នោតសរុបឡើយ។



### ឯកជនភាពនិងការរក្សាការសម្ងាត់

ព័ត៌មានរបស់អ្នកបោះឆ្នោតនៅលើបញ្ជីបោះឆ្នោតអេឡិចត្រូនិច (E-pollbooks) មិនត្រូវបានភ្ជាប់ទៅនឹង BMD ឬប្រព័ន្ធប្ញកសរុបការបោះឆ្នោតឡើយ ។ បញ្ជីទាំងនេះនៅឯករាជ្យពីគ្នាដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកបោះឆ្នោត ។ សន្លឹកឆ្នោតដែលបានបោះពុម្ពមិនមានព័ត៌មានរបស់អ្នកបោះឆ្នោតទេ ។



### ការត្រួតពិនិត្យសិទ្ធិប្រើប្រាស់ពហុលក្ខណៈ

ការិយាល័យអ្នកចុះបញ្ជី-អ្នកកត់ត្រា/ស្មៀនខោនធីនៃខោនធី Los Angeles រក្សានូវរបៀបរបបសុវត្ថិភាពសមស្របនៅដំណាក់កាលនីមួយៗក្នុងដំណើរការនៃការបោះឆ្នោត។ បុគ្គលិកបោះឆ្នោតមានព័ត៌មានសម្ងាត់របស់អ្នកប្រើប្រាស់ជាក់លាក់ ដើម្បីកាត់បន្ថយភាពដែលអាចកើតមានការប្រើប្រាស់ដែលគ្មានការអនុញ្ញាត។ ការប្រើប្រាស់សោរ និងត្រាសម្គាល់ដើម្បីការពារការរុះរើនៅលើហិបឆ្នោតដែលមានលក្ខណៈរួមបញ្ចូល (IBB) ហើយគ្រឿងបរិក្ខារការបោះឆ្នោតដែលឆាប់ញោច ការពារបាននូវសេចក្តីសុចរិតនៃការបោះឆ្នោត និងធានាបាននូវខ្សែចង្វាក់នៃការរក្សាទុកដែលអាចផ្ទៀងផ្ទាត់បាន ។



### តម្លាភាពនិងលទ្ធភាពចេញចូល

បទពិសោធន៍ក្នុងការបោះឆ្នោតថ្មីបានរួមបញ្ចូលនូវការការពារចាំបាច់ប្រឆាំងនឹងភាពទន់ខ្សោយរបស់ប្រព័ន្ធ ព្រមទាំងធានាឱ្យបាននូវតម្លាភាព និងសិទ្ធិប្រើប្រាស់ជាសាធារណៈសម្រាប់ដំណើរការនៃការបោះឆ្នោត ដោយធ្វើសវនកម្មដោយផ្ទាល់ដៃលើសន្លឹកឆ្នោតដែលបានបោះចំនួន 1% ក្នុងរយៈពេលក្រោយការបោះឆ្នោត មុននឹងធ្វើការបញ្ជាក់។



Rev. 4/2022